ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេររដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ.) ឱ្យស្ថិតនៅក្រោមអាណាព្យាបាលនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

☆☆☆☆☆

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពី លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ. បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ. បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ.)
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ. បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០០០ ស្តីពី ការកែសំរួលអនុក្រឹត្យលេខ ៥២ អនក្រ. បក ស្តីពី ការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១.-**

ផ្ទេររដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ.) ដែលស្ថិតនៅក្រោមអាណាព្យាបាល នៃសាលាក្រុងភ្នំពេញ ឱ្យមកស្ថិតនៅក្រោមអាណាព្យាបាលនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលវិញ ។

**មាត្រា ២.-**

ភារកិច្ចទាំងឡាយណារបស់សាលាក្រុងភ្នំពេញ ដែលមានចែងក្នុងអនុក្រឹត្យលេខ ៥២ អនក្រ. បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ.) និង អនុក្រឹត្យ លេខ ៣៤ អនក្រ. បក ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០០ ស្តីពី ការកែសំរួលអនុក្រឹត្យ លេខ ៥២ អនក្រ. បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ត្រូវផ្ទេរមកក្រោមសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

តំណាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល មានមុខងារជាប្រធានក្រុមប្រឹក្សាភិបាល ។ តំណាងសាលាក្រុងភ្នំពេញ មានមុខងារជាសមាជិកក្រុមប្រឹក្សាភិបាល ។

**មាត្រា ៣.-**

រាល់បទប្បញ្ញត្តិណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អភិបាលក្រុងភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យ នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

គោរពជំរាបជូន សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រីក្រសួង
ឧស្សាហកម្ម រ៉ែ និង ថាមពល

ស៊ុយ សែម

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- ឯកសារ - កាលប្បវត្តិ ។